ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D361/4/1/10

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៦)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 11 / 2017
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ: កោសលុប

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលារៀបចំឲ្យបានគ្រប់គ្រាន់

**សហព្រះរាជអាជ្ញា:**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍ ÷**
សូ មូស្សេទ្ធី
Suzana TOMANOVIĆ
Neville SORAB

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ÷**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATH

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * E.C.C.C. * C.E.T.C.

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល"បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលាសម្រាប់រៀបចំឱ្យបានគ្រប់គ្រាន់" ដាក់ដោយសហមេធាវីការពារក្តី("មេធាវីការពារក្តី") [redacted] ("ម្ចាស់បណ្តឹងឧទ្ធរណ៍") នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

១. បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធនឹងដីកាសម្រេច ដែលចេញដោយសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ដែលបដិសេធសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំពន្យារពេលយ៉ាងហោចណាស់ ៦ ខែ ចំពោះពេលវេលាកំណត់សម្រាប់ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦(១) ("ដីកាសម្រេចដែលរងការជំទាស់")[2]។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ("ស.ព.អ") បានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយចោទថា ម្ចាស់បណ្តឹងឧទ្ធរណ៍ បានចូលរួមអំពើឧក្រិដ្ឋ ហើយស្នើសុំដាក់គាត់ស្ថិតក្រោមការពិនិត្យលើបទចោទនានា[3]។

៣. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានជូនដំណឹងភាគីទាំងអស់ថា ស.ច.ស យល់ឃើញថា កិច្ចស៊ើបសួរលើម្ចាស់បណ្តឹងឧទ្ធរណ៍ បានបិទបញ្ចប់

---

[1]សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលាសម្រាប់រៀបចំឱ្យបានគ្រប់គ្រាន់ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4/1/5 ("បណ្តឹងឧទ្ធរណ៍") ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៧ និងជាភាសាខ្មែរ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧។

[2]សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលាសម្រាប់រៀបចំឱ្យបានគ្រប់គ្រាន់ ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4 ("ដីកាសម្រេចដែលរងការជំទាស់") កថាខណ្ឌ ៣៩-៤១។

[3]សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤ *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។



E.C.C.C PRE-TRIAL CHAMBER

ហើយបានជូនដំណឹងថា សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតអាចដាក់បាន យោងតាមវិធានផ្ទៃក្នុង ៦៦(១) ក្នុងរយៈពេល ១៥ ថ្ងៃ ចាប់ពីថ្ងៃចេញសេចក្ដីជូនដំណឹងនេះ("សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ")[4]។ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ មេធាវីការពារក្ដីបានដាក់សំណើសុំពន្យារពេលដែលបានកំណត់នៅក្នុងវិធានផ្ទៃក្នុង ៦៦(១) យ៉ាងហោចណាស់ឱ្យបានរយៈពេល ៦ ខែ ចាប់ពីថ្ងៃចេញសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ("សំណើ")[5]។ នៅថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧ ស.ច.ស បានចេញដីកាសម្រេចដែលរងការជំទាស់ ដោយអនុញ្ញាតឱ្យពន្យារពេលតែ ៣០ ថ្ងៃប៉ុណ្ណោះ ហេតុនេះកំណត់កាលបរិច្ឆេទថ្មីគឺនៅត្រឹមថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧[6]។ នៅថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្ដី បានដាក់ជូន ក.ស.ច.ស នូវសេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចដែលរងការជំទាស់[7] ហើយនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្ដី បានដាក់ជូនអង្គបុរេជំនុំជម្រះនូវសំណើសុំព្យួរការអនុវត្តកាលកំណត់តាមដីកាសម្រេចដែលរងការជំទាស់ ដោយរង់ចាំសាលដីកាលើបណ្ដឹងឧទ្ធរណ៍សិន ("សំណើសុំព្យួរការអនុវត្ត")[8]។ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះបានបដិសេធសំណើសុំព្យួរការអនុវត្ត ដោយសម្រេចថា៖

> "អ្នកស្នើសុំ ពុំបានបង្ហាញពីកាលៈទេសៈពិសេសនានា ដែលផ្ដល់យុត្តិកម្មដល់ការព្យួរដីកាសម្រេចដែលរងការជំទាស់ មុនពេលដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនឡើយ។ ជាពិសេស ពុំមានការបង្ហាញថា ការអនុវត្តទៅតាមកាលបរិច្ឆេទកំណត់ដែលមាននៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរ នឹងធ្វើឱ្យប៉ះពាល់ដល់គោលបំណងនៃបណ្ដឹងឧទ្ធរណ៍ នៅពេលអនាគត ឬបង្កើតជាស្ថានភាពដែលមិនអាច

[4]សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ [redacted] ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D358 កថាខណ្ឌ ៧-៨។

[5]សំណុំរឿង ០០៤ សំណើរបស់ [redacted] សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D361 ("សំណើ") ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៧ និងជាភាសាខ្មែរ នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧ ទំព័រ ១៥។

[6]ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤០, ៤១។

[7]សំណុំរឿង ០០៤ ការជូនដំណឹងរបស់ [redacted] អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4/1 ជូនដំណឹងនៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១៧។

[8]សំណុំរឿង ០០៤ សំណើរបស់ [redacted] សុំព្យួរការអនុវត្តតាមកាលកំណត់ក្នុងដីកាសម្រេច D361/4 ដោយរង់ចាំសេចក្ដីសម្រេចនៃនីតិវិធីបណ្ដឹងឧទ្ធរណ៍ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4/1/1 ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ និងជាភាសាខ្មែរ នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៧ ទំព័រ ៦។

តែប្រែបាន ដូចជា ការអនុវត្តដីកាសម្រេចដែលរងការជំទាស់ ដែលនឹងមានឥទ្ធិពលដោយផ្ទាល់ទៅលើប្រសិទ្ធភាព និងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីបណ្ដឹងឧទ្ធរណ៍នោះឡើយ។ តាមពិតទៅ ប្រសិនបើបណ្ដឹងឧទ្ធរណ៍ទទួលបានជោគជ័យលើអង្គសេចក្ដីនៃបណ្ដឹងនេះ អ្នកស្នើសុំនឹងទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំ និងដាក់សំណើបន្ថែម ដែលគាត់យល់ថាជាការចាំបាច់"[9]។

៤. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្ដី បានដាក់បណ្ដឹងឧទ្ធរណ៍តែជាភាសាអង់គ្លេសសិន ហើយស្នើសុំដាក់សំណៅបកប្រែជាភាសាខ្មែរ នៅពេលក្រោយ[10]។ បណ្ដឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៧ ចំណែកឯសំណៅបកប្រែជាភាសាខ្មែរវិញ ត្រូវបានដាក់ និងជូនដំណឹងនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧។

៥. នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស បានចេញ "សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើករណី [redacted]" ("សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ")[11] ដោយបញ្ជាក់ថា ការផ្ដល់ពេលវេលាបន្ថែមទៀត បន្ទាប់ពីដាក់សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរនេះ គឺជាវិធានការពិសេស ដែលស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់ ស.ច.ស អាស្រ័យជាចម្បងលើចំនួន និងគុណភាពភស្ដុតាងដែលប្រមូលបានបន្ទាប់ពីចេញសេចក្ដីជូនដំណឹងលើកទី ១ អំពីការបិទកិច្ចស៊ើបសួរ[12] ហើយបានជូនដំណឹងភាគីទាំងអស់ថា "តាមវិធានផ្ទៃក្នុង មិនតម្រូវឱ្យទុកពេលសម្រាប់កិច្ចស៊ើបសួរបន្ថែមទៀតទេ ហេតុនេះ មិនផ្ដល់ជូនពេលវេលាបន្ថែមទៀតទេ"[13]។

---

[9]សំណុំរឿង ០០៤ សេចក្ដីសម្រេចលើសំណើរបស់ [redacted] សុំពន្យារការអនុវត្តតាមកាលកំណត់ក្នុងដីកាសម្រេច D361/4 ដោយរង់ចាំសេចក្ដីសម្រេចនៃនីតិវិធីបណ្ដឹងឧទ្ធរណ៍ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4/1/3 ("សេចក្ដីសម្រេចលើសំណើសុំពន្យារការអនុវត្ត") កថាខណ្ឌ ៥។

[10]សំណុំរឿង ០០៤ សំណើសុំការអនុញ្ញាតដើម្បីដាក់បណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលាសម្រាប់រៀបចំឱ្យបានគ្រប់គ្រាន់ តែមួយភាសា ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4/1/4 ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៧។

[11]សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ [redacted] ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D368 ("សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ")។

[12]សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ កថាខណ្ឌ ២១។

[13]សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ កថាខណ្ឌ ២៨។

៦. នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ព.អ បានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ តែជាភាសាអង់គ្លេសសិន ហើយស្នើសុំដាក់សំណៅបកប្រែជាភាសាខ្មែរ នៅពេលក្រោយ[14]។ ចម្លើយតបរបស់ ស.ព.អ ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧ ("ចម្លើយតប")[15]។

៧. នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់ការឆ្លើយតបទៅនឹងចម្លើយតប តែជាភាសាអង់គ្លេសសិន ហើយស្នើសុំដាក់សំណៅបកប្រែជាភាសាខ្មែរ នៅពេលក្រោយ[16]។ ការឆ្លើយតប ត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ចំណែកឯសំណៅបកប្រែជាភាសាខ្មែរវិញ ត្រូវបានដាក់ និងជូនដំណឹងនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៧ ("ការឆ្លើយតប")[17]។

## III. ភាពអាចទទួលយកបាន

### ១. សារណា

៨. មេធាវីការពារក្តី "ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ [...] ទទួលយកបណ្តឹងឧទ្ធរណ៍នេះ"[18] ដោយបញ្ជាក់ថា បណ្តឹងឧទ្ធរណ៍នេះ"អាចទទួលបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ពីព្រោះថា ដីកា

[14] សំណុំរឿង ០០៤ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចស្តីពីពេលវេលាបន្ថែម តែមួយភាសា ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D361/4/1/6។

[15] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើពេលវេលាបន្ថែម ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D361/4/1/7 ជូនដំណឹងនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧។

[16] សំណុំរឿង ០០៤ សំណើសុំការអនុញ្ញាតដើម្បីដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ តែមួយភាសា ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D361/4/1/8។

[17] សំណុំរឿង០០៤ ការឆ្លើយតបរបស់ [redacted] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧ ឯកសារ D361/4/1/8។

[18] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៩៧(១)។

សម្រេចដែលរងការជំទាស់ រំលោភសិទ្ធិជាសារវ័ន្តរបស់ [redacted] ដើម្បីទទួលបានពេលវេលាគ្រប់គ្រាន់ សមភាពនៃសិទ្ធិ និងភាពយុត្តិធម៌នៃនីតិវិធី”[19]។

៩. ជាដំបូង មេធាវីការពារក្តីទទួលស្គាល់ថា (i) បណ្តឹងឧទ្ធរណ៍នេះ“មិនស្ថិតនៅពិតប្រាកដក្រោម [...] វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុងឡើយ”[20] (ii) “វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបង្កើតជាផ្លូវស្វ័យប្រវត្តិសម្រាប់ការប្តឹងឧទ្ធរណ៍ទេ”[21] និង(iii)“ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបង្ហាញថា [...] អន្តរាគមន៍របស់ [អង្គបុរេជំនុំជម្រះ] គឺចាំបាច់ ដើម្បីបញ្ចៀសផលខូចខាត ដែលមិនអាចជួសជុលបានដល់ភាពត្រឹមត្រូវយុត្តិធម៌នៃការស៊ើបអង្កេត ឬកិច្ចដំណើរការនីតិវិធី ឬសិទ្ធិជាសារវ័ន្តរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍”[22]។ ប៉ុន្តែ មេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា “សម្រាប់គោលបំណងនៃភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ជាជាងលើអង្គសេចក្តី វាមានភាពគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណ ជាជាងការបង្ហាញពីបញ្ហាដែលពាក់ព័ន្ធ”[23]។ មេធាវីការពារក្តី បន្ថែមថា “ការខកខានមិនទទួលយកបណ្តឹងឧទ្ធរណ៍នេះ [...] នឹងបង្កើតបានជាការរំលោភបំពានសិទ្ធិ”[24] ពីព្រោះថា “សហព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍“ដីកាសម្រេចទាំងអស់”របស់ ស.ច.ស ក្រោមវិធាន ៧៤(២)នៃវិធានផ្ទៃក្នុង [និង] សិទ្ធិសមភាពនៅចំពោះមុខតុលាការ [...] ទាមទារឲ្យមេធាវីការពារក្តីទទួលបានដំណើរការនីតិវិធី នៅចំពោះមុខ [អង្គបុរេជំនុំជម្រះ] ដូចសហព្រះរាជអាជ្ញាដែរ”[25]។

១០. ពាក់ព័ន្ធនឹង “សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំតាមរយៈការចូលរួមឲ្យបានត្រឹមត្រូវនៅក្នុងកិច្ចស៊ើបសួរ”[26] មេធាវីការពារក្តីបញ្ជាក់ថា “ដោយអនុលោមតាមច្បាប់អន្តរជាតិ ដែលមានភាពស្របគ្នា ស.ច.ស មានកាតព្វកិច្ចផ្តល់ពេលវេលាបន្ថែមសម្រាប់រៀបចំ ដូចដែលបាន ស្នើឡើង

---

[19]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[20]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

[21]ដូចដើងទំព័រខាងលើ។

[22]ដូចដើងទំព័រខាងលើ។

[23]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣២ ដោយយោងលើដីកាសម្រេចដាក់ [redacted] ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ កថាខណ្ឌ ១៧។

[24]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣។

[25]ដូចដើងទំព័រខាងលើ ។

[26]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤។



E.C.C.C * C.E.T.C.
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ដោយសមហេតុផល"[27] ហើយមេធាវីការពារក្តី បន្ថែមទៀតថា កាតព្វកិច្ចនេះ "មាន សារៈសំខាន់ ជាពិសេស ដោយហេតុថា [redacted] ប្រឈមនឹងការចោទប្រកាន់ព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុត និងដោយសារតែទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង"[28]។ ជាងនេះទៀត ដើម្បីផ្តល់ទឡ្ហីករណ៍ថា "ឱកាសតែមួយគត់ ដែល[មេធាវីការពារក្តី]មានដើម្បីពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង ០០៤ និង ដាក់ញត្តិត្រឹមត្រូវគឺក្នុងអំឡុងពេលស៊ើបសួរ"នោះ ទីមួយ មេធាវីការពារក្តី បង្ហាញថា៖ (i) វិធាន ផ្ទៃក្នុង ៧៦(៧) មិនឱ្យ"បញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធី [...] ត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ"[29] និងទីពីរ (ii) កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២ បញ្ជាក់ថា "អង្គជំនុំជម្រះសាលាដំបូង [...] សង្ឃឹមថា នៅក្នុងដំណាក់កាលស៊ើបសួរ មេធាវីការពារក្តី នឹងពិនិត្យមើលភ័ស្តុតាងនៅក្នុងសំណុំរឿង រហូតដល់ពេលវេលាដែលពួកគេរួចរាល់សម្រាប់ការជំនុំជម្រះ ហើយនឹងមិនលើកអំពីបញ្ហាពាក់ព័ន្ធនឹងការស៊ើបសួរ នៅអំឡុងពេលជំនុំជម្រះឡើយ" [30]។

១១. នៅក្នុងការលើកឡើងអំពីបញ្ហាសមភាពនៃមធ្យោបាយតទល់ក្តី ជាដំបូង មេធាវីការពារក្តីបញ្ជាក់ថា ខ្លួន"មិនអះអាង [...] ថា ខ្លួនត្រូវការពេលវេលាដូចគ្នាជាមួយសំណុំរឿង ដូច ស.ព.អ ទេ"[31]។ មេធាវីការពារក្តី អះអាងថា "[redacted] នឹងស្ថិតនៅក្នុងស្ថានភាពចាញ់ប្រៀបផ្នែកនីតិវិធីសំខាន់មួយក្នុងការតទល់ជាមួយសហព្រះរាជអាជ្ញា ប្រសិនបើមេធាវីការពារក្តីមិនទទួលបានឱកាសគ្រប់គ្រាន់ដើម្បីស្វែងយល់ដឹងអំពីសំណុំរឿង ដែលខ្លួនអាចមានលទ្ធភាពធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរចាំបាច់ទាំងអស់ និងញត្តិចាំបាច់ផ្សេងៗ មុននឹងការបញ្ចប់ការស៊ើបសួរ"[32]។

---

[27]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។ សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤-៣៥ ដោយយោងលើយុត្តិសាស្ត្រអន្តរជាតិ ជាពិសេស គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ៖ "ការដាក់កំហិតនីតិវិធីដែលអាចមានផលប៉ះពាល់ដល់សមត្ថភាព[របស់គាត់]" ដើម្បីស្វែងរកភ័ស្តុតាងជំនួសរូបគាត់ ត្រូវបានគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ រកឃើញថា ផ្ទុយនឹងសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់"។

[28]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។

[29]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦។

[30]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦ ដោយយោងលើសំណុំរឿង ០០២ ប្រតិចារិកសវនាការ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E1/123.1។

[31]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨។

[32]បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩។

១២. ចុងក្រោយបង្អស់ ពាក់ព័ន្ធនឹងបញ្ហាភាពយុត្តិធម៌នីតិវិធី មេធាវីការពារក្ដីអះអាងថា ខ្លួន"ត្រូវបានទប់ស្កាត់ដោយមិនត្រឹមត្រូវយុត្តិធម៌ពីការបំពេញនូវភារកិច្ចវិជ្ជាជីវៈមូលដ្ឋានរបស់ខ្លួន"[33] ដោយសារ"ការដាក់បញ្ចូលមេធាវីការពារក្ដីដោយយឺតយ៉ាវពេកទៅក្នុងសំណុំរឿង ០០៤"[34] បន្ទាប់មកក្រោយពីបានដាក់បញ្ចូលហើយ មាន"ពេលវេលាមិនគ្រប់គ្រាន់ដើម្បីស្វែងយល់ដឹងអំពីសំណុំរឿងមុនពេលវេលាកំណត់សម្រាប់ការធ្វើសំណើសុំធ្វើកិច្ចស៊ើបសួរ និងញត្តិចាំបាច់ផ្សេងៗទៀត"[35]។ មេធាវីការពារក្ដីបញ្ជាក់ថា "ការខកខានក្នុងការពិចារណាឲ្យបានត្រឹមត្រូវលើភាពត្រឹមត្រូវយុត្តិធម៌នៃកាលៈទេសៈ ដែលបង្កើតឡើងតាមរយៈការបិទកិច្ចស៊ើបសួរនៅដំណាក់កាលនេះ ចៅក្រមប្រឈមនឹងការប្រព្រឹត្តិ*តាមអង្គហេតុ*[...] ដែលលើកកម្ពស់ផលប្រយោជន៍របស់ ស.ព.អ ជាងផលប្រយោជន៍របស់មេធាវីការពារក្ដី។ ចំណុចនេះគឺមិនអាចទទួលយកបានឡើយ"[36]។ តាមការយល់ឃើញរបស់មេធាវីការពារក្ដី "ក្ដីបារម្ភទាក់ទងនឹងការប្រព្រឹត្តិដោយរហ័ស និងត្រឹមត្រូវនៃសំណុំរឿង [...] មិនអាច [...] ធ្វើជាយុត្តិកម្មដើម្បីបញ្ចប់កិច្ចស៊ើបសួរ ដោយប្រញាប់ដោយមិនបានផ្ដល់ពេលវេលាគ្រប់គ្រាន់ដល់ [redacted] ដើម្បីចូលរួមនោះទេ [...បញ្ហានេះ] មិនអាចត្រូវបានគ្របដណ្ដប់ដោយសិទ្ធិដែលផ្ទុយតាមការសន្មតរបស់ភាគីដទៃទៀតឡើយ"[37]។ ជាងនេះទៀត មេធាវីការពារក្ដីបញ្ជាក់ថា "ស.ច.ស ប្រឈមនឹងគ្រោះថ្នាក់ជាសក្ដានុពលនៃសិក្ខាបទនៃភាពត្រឹមត្រូវយុត្តិធម៌ផ្នែកនីតិវិធី ដោយខកខានមិនបានផ្ដល់សំអាងហេតុដែលទាក់ទង និងត្រឹមត្រូវនៅក្នុងដីកាសម្រេចដែលរងការជំទាស់ ដូចជា ថា [redacted] ត្រូវបានផ្ដល់ជូននូវសិទ្ធិត្រឹមត្រូវក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព"[38]។

---

[33]បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤១៖ "តាមរយៈការគ្រប់គ្រងសំណុំរឿង ០០៤ ពីមុនមក [...] [redacted] ត្រូវបានដកចេញពីការចូលរួមក្នុងការស៊ើបអង្កេតរហូតដល់ដំណាក់កាលចុងក្រោយទៅហើយ" (និងជើងទំព័រ ៥៤ ផ្នែកគាំពារការការពារក្ដី និងបន្ទាប់មក មេធាវីការពារក្ដី បានទាមទារសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤ ដើម្បីស្វែងរកការការពារសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌ជាសារវន្តរបស់ [redacted] រួមទាំងស្វែងរកការរក្សានូវសមភាពមធ្យោបាយនៃការតទល់ក្ដីពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១០ រហូតដល់អាចចូលពិនិត្យសំណុំរឿងបាន ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៥")។

[34]ដូចជើងទំព័រខាងលើ។

[35]ដូចជើងទំព័រខាងលើ។

[36]បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤២។

[37]បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។

[38]បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤។

១៣. ជាការឆ្លើយតប ស.ព.អ បញ្ជាក់ថា បណ្ដឹងឧទ្ធរណ៍ "ខកខានមិនត្រឹមត្រូវទៅតាមការកម្រិតយ៉ាងតិចនៃការទទួលយកបណ្ដឹងឧទ្ធរណ៍"[39] យោងតាមវិធាន ២១ នៃវិធានផ្ទៃក្នុងទេ ហើយបណ្ដឹងឧទ្ធរណ៍ "មិនបានបញ្ជាក់ពីការអះអាងណាមួយក្នុងចំណោមការអះអាង"[40] អំពីការរំលោភបំពានសិទ្ធិរបស់ [redacted] ក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី និងសមភាពនៃមធ្យោបាយតទល់ក្ដី ឬក៏អំពីកង្វះភាពយុត្តិធម៌នីតិវិធីដែរ។ ជាការឆ្លើយតបទៅនឹងការអះអាងរបស់មេធាវីការពារក្ដីដែលថា ក្នុងគោលបំណងដើម្បីឱ្យបណ្ដឹងឧទ្ធរណ៍អាចទទួលយកបាននោះ គឺគ្រប់គ្រាន់ហើយត្រឹមបង្ហាញបញ្ហាពាក់ព័ន្ធ ជាជាងបញ្ជាក់ភស្តុតាងពីបញ្ហាពាក់ព័ន្ធនោះ ស.ព.អ អះអាងថា "ការគ្រាន់តែពឹងផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តែមួយមុខនោះ ដោយពុំបានបង្ហាញថាតើសិទ្ធិទាំងនោះអនុវត្តយ៉ាងណាចំពោះកាលៈទេសៈ ដែលសិទ្ធិទាំងនោះជាប់ពាក់ព័ន្ធនោះគឺច្បាស់ជាមិនគ្រប់គ្រាន់ទេ សម្រាប់គោលបំណងទទួលយកបណ្ដឹងឧទ្ធរណ៍"[41]។ ស.ព.អ រំឭកថា "ការខកខានមិនបានរៀបរាប់ថាតើសិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី ត្រូវរងផលប៉ះពាល់ជាក់ស្ដែងយ៉ាងណានោះ គឺគ្រប់គ្រាន់ធ្វើឱ្យបណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបានយោងតាមវិធាន ២១ នៃវិធានផ្ទៃក្នុង"[42] ហើយ "បណ្ដឹងឧទ្ធរណ៍មួយនៅក្រោមវិធាន ២១ ដែលមិនប្រាកដប្រជា គឺមិនអាចទទួលយកបាននោះទេ"[43]។ ចុងក្រោយបង្អស់ ស.ព.អ បញ្ជាក់ថា ការបដិសេធមិនព្រមទទួលយកបណ្ដឹងឧទ្ធរណ៍ ជាក់ស្ដែងនឹងមិនលើកតម្កើងផលប្រយោជន៍របស់សហព្រះរាជអាជ្ញាទេ[44] ហើយ"ប្រឆាំងទៅនឹងគោលបំណងនៃវិធាន ៧៤(៣)"[45]។

[39]ចម្លើយតប កថាខណ្ឌ ១។

[40]ចម្លើយតប កថាខណ្ឌ ៧។

[41]ចម្លើយតប កថាខណ្ឌ ៨។

[42]ចម្លើយតប កថាខណ្ឌ ៩ ដោយយោងលើឯកសារ D208/1/1/2 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១២។

[43]ចម្លើយតប កថាខណ្ឌ ១២ ដោយយោងលើឯកសារ D284/1/4 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60។

[44]ចម្លើយតប កថាខណ្ឌ ១៥ ដោយយោងលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣។

[45]ដូចជើងទំព័រខាងលើ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

១៤. ស.ព.អ បញ្ជាក់ថែមទៀតថា [redacted] មិនបានបង្ហាញថា តើសិទ្ធិរបស់គាត់ក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ត្រូវបានរំលោភបំពានយ៉ាងណានោះទេ[46] ហេតុនេះ "បណ្តឹងឧទ្ធរណ៍នេះត្រូវបានយល់ឃើញថាខ្វះលក្ខណៈប្រាកដប្រជា"[47]។ ត្រង់នេះ ស.ព.អ បញ្ជាក់ថា "[redacted] មិនពន្យល់ពីស្ថានភាពបច្ចុប្បន្ននេះនៃការពិនិត្យភ័ស្តុតាងឡើងវិញ[របស់ខ្លួន] ថា ហេតុអ្វីបានជាក្រុមមេធាវីការពារក្តី មិនមានលទ្ធភាពពិនិត្យភ័ស្តុតាងនោះឡើងវិញ[...] ចាប់តាំងពី[នៅពេលដែល] ខ្លួនត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ឬក៏ថា ហេតុអ្វីបានជាការពន្យារពេល ៣០ ថ្ងៃ [...] គឺវាមិនគ្រប់គ្រាន់ និងថាហេតុអ្វីបានជាប្រាំមួយខែដែលបានស្នើសុំនោះវាចាំបាច់"[48]។ ស.ព.អ អះអាងថែមទៀតថា "មានការចង្អុលបង្ហាញនីមួយៗថា [redacted] មានពេលវេលាគ្រប់គ្រាន់"[49] ពីព្រោះថា គាត់ "អាចចូលមើលសំណុំរឿងបានជាង ១៨ ខែ"[50] គាត់មាន "ធនធាន"[51] ហើយគាត់ "ត្រូវបានជូនដំណឹងអំពីក្របខណ្ឌពេលវេលានៃគម្រោងបញ្ចប់កិច្ចស៊ើបសួរ"[52]។ តាមការយល់ឃើញរបស់ ស.ព.អ [redacted] "បានជ្រើសរើសមិន"ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ នៅក្នុងអំឡុងពេលនោះទេ[53]។

១៥. ពាក់ព័ន្ធនឹងបញ្ហាសមភាពរវាងគូភាគីក្តី ស.ព.អ សន្និដ្ឋានថា [redacted] ខកខានមិនបាន "កំណត់អត្តសញ្ញាណថាតើរបៀបណាដែលការបដិសេធសំណើរបស់គាត់សុំពន្យារពេលប្រាំមួយខែ នឹងត្រូវដាក់គាត់ស្ថិតនៅក្នុងក្រោមការខូចខាតប្រយោជន៍បែបដូច្នេះនោះទេ"[54]។

---

[46]ចម្លើយតប កថាខណ្ឌ ៩។

[47]ចម្លើយតប កថាខណ្ឌ ១២។

[48]ចម្លើយតប កថាខណ្ឌ ៩។

[49]ចម្លើយតប កថាខណ្ឌ ១០។

[50]ដូចជើងទំព័រខាងលើ។

[51]ចម្លើយតប កថាខណ្ឌ ១០ "សំណើ និងឯកសារចំនួន ៥១ ច្បាប់ដែលបានដាក់ដោយ [redacted] នៅក្នុងអំឡុងពេលនេះ បញ្ជាក់ [...]"។

[52]ចម្លើយតប កថាខណ្ឌ ១១ ដោយយោងលើដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៤៖ "មេធាវីការពារក្តី ត្រូវបានជូនដំណឹងអំពីក្របខណ្ឌពេលវេលានៃគម្រោងបញ្ចប់កិច្ចស៊ើបសួរតាមរយៈផែនការបញ្ចប់ការងារដែលបានចេញផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក"។

[53]ចម្លើយតប កថាខណ្ឌ ១០។

[54] ចម្លើយតប កថាខណ្ឌ ១៣ យោងលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨ ដល់ កថាខណ្ឌ ៣៩។

១៦. នៅពេលលើកឡើងអំពីបញ្ហានៃភាពយុត្តិធម៌ផ្នែកនីតិវិធី ស.ព.អ សន្និដ្ឋានថា ទឡ្ហីករណ៍របស់ [redacted] អំពីសិទ្ធិចូលពិនិត្យសំណុំរឿងយឺតយ៉ាវ ដែលរារាំងគាត់មិនឱ្យចូលនៅក្នុងនៅក្នុងការស៊ើបអង្កេត "យឺតយូរ" ដោយសារបណ្តឹងលម្អិតខ្លាំងពេករបស់មេធាវីការពាក្តី នៅក្នុងអំឡុងពេលដែលពួកគេមានសិទ្ធិចូលពិនិត្យមើល[55]។ ម្យ៉ាងវិញទៀត ស.ព.អ ផ្តល់ទឡ្ហីករណ៍ថា ការអះអាងរបស់មេធាវីការពារក្តីថា ស.ច.ស ខកខានមិនបានផ្តល់សំអាងហេតុសមស្របគឺជា "ការយល់ខុស" ហើយបណ្តឹងឧទ្ធរណ៍នោះពុំរៀបរាប់លម្អិត ថាតើសេចក្តីសម្រេចទំនងជាគ្មានសំអាងហេតុយ៉ាងដូចម្តេច ហើយថាតើវាពាក់ព័ន្ធនឹងភាពយុត្តិធម៌ផ្នែកនីតិវិធីដោយរបៀបណា[56]។

១៧. មេធាវីការពារក្តីឆ្លើយតបថា "ស.ព.អ កំណត់លក្ខណៈមិនត្រឹមត្រូវលើទឡ្ហីករណ៍របស់មេធាវីការពារក្តីនៅក្នុងចម្លើយតបរបស់ខ្លួនដើម្បីព្យាយាមច្រានចោលទឡ្ហីករណ៍ទាំងនោះ"[57] ហើយមេធាវីការពារក្តីនៅតែសន្និដ្ឋានដដែលៗថា "បណ្តឹងឧទ្ធរណ៍មានសំអាងត្រឹមត្រូវ"[58]។ មេធាវីការពារក្តីតវ៉ាថា ការពិចារណាលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះស្តីពីលក្ខខណ្ឌអប្បបរមាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ គឺ "ជ្រើសរើសជ្រុល"[59]។ ពាក់ព័ន្ធនឹងទឡ្ហីករណ៍លើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿងដូចគ្នានឹង ស.ព.អ ដែលបានដាក់ជូនអង្គជំនុំជម្រះនេះក្នុងនាមជាតុលាការកំពូល មេធាវីការពារក្តីសន្និដ្ឋានថា "ស.ព.អ អាន វិធាន ៧៤ នៃ[វិធានផ្ទៃក្នុង] ដាច់ដោយឡែក ដោយមិនបានពិចារណាលើវិធាន ៧៤(២)នៃ[វិធាន]ផ្ទៃក្នុង និងសេចក្តីសម្រេចរបស់[អង្គជំនុំជម្រះ] កាលពីលើកមុន[...]ពាក់ព័ន្ធនឹងវិធាន ២១ នៃ[វិធានផ្ទៃក្នុង]"[60]។

១៨. មេធាវីការពារក្តីសន្និដ្ឋានបន្ថែមទៀតថា តាមរយៈ "ការសង្កេតឃើញថា "ការស៊ើបអង្កេតកាន់តែយូរ ភាគីត្រូវការពេលកាន់តែច្រើនស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ" [ស.ព.អ] ពុំពិចារណាលើការមិនរួមបញ្ចូលមេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេតរហូតមកដល់ខែធ្នូ ឆ្នាំ ២០១៥ [...] ហេតុ

---

[55] ចម្លើយតប កថាខណ្ឌ ១៤។

[56] *ដូចខាងលើ*។

[57] ការឆ្លើយតប កថាខណ្ឌ ១០។

[58] ការឆ្លើយតប កថាខណ្ឌ ១១។

[59] ការឆ្លើយតប កថាខណ្ឌ ១២។

[60] ការឆ្លើយតប កថាខណ្ឌ ១៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ដូច្នេះ វាបង្ហាញយ៉ាងត្រឹមត្រូវនូវអសមភាពផ្នែកនីតិវិធីនៅក្នុងរឿងក្តីនេះ"[61]។ មេធាវីការពារក្តីបញ្ជាក់បំភ្លឺថា "ដើម្បីជាគោលបំណងនៃការវាយតម្លៃពេលវេលាសមស្រប [មេធាវីការពារក្តី] សំអាងលើរយៈពេលនៃការស៊ើបអង្កេតទាំងអស់ (ដែលនៅក្នុងអំឡុងពេលនោះ ការិយាល័យសហព្រះរាជអាជ្ញាមានសេរីភាពធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរនៅពេលណាក៏បាន) មិនត្រឹមតែក្នុងរយៈពេលដែលមេធាវីការពារក្តីបានទទួលសិទ្ធិចូលពិនិត្យមើលសំណុំរឿងនោះទេ"[62]។ ចំណុចចុងក្រោយ មេធាវីការពារក្តីនៅតែសន្និដ្ឋានថា "សេចក្តីសម្រេចដែលរងការជំទាស់ពុំមានសំអាងហេតុគ្រប់គ្រាន់ ហើយទឡ្ហីករណ៍របស់ ស.ព.អ មិនអាចយកមកជំនួសសំអាងហេតុនេះបានសមស្របនោះទេ"[63]។

## ២. កិច្ចពិភាក្សា

១៩. នៅពេលឯកភាពលើការទទួលស្គាល់របស់មេធាវីការពារក្តី អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បណ្តឹងឧទ្ធរណ៍នេះពុំស្ថិតក្នុងក្របខណ្ឌវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុងនោះទេ ហើយវិធាន ២១ នៃវិធានផ្ទៃក្នុងពុំបានបង្កើតយន្តការបើកឲ្យប្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិនោះឡើយ។ ពាក់ព័ន្ធនឹងយុត្តិសាស្ត្រដែលបានសំអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ដើម្បីតវ៉ាថា "សម្រាប់គោលបំណងនៃភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ [អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង]...វាមានភាពគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណជាជាងការបង្ហាញពីបង្ហាញដែលពាក់ព័ន្ធ"[64] អង្គជំនុំជម្រះនៅចាំថា ខ្លួនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍ស្រដៀងគ្នានេះ នៅក្នុងសេចក្តីសម្រេចមុនមួយ[65] ដែលខ្លួនបានលើកឡើងថា៖

---

[61] ការឆ្លើយតប កថាខណ្ឌ ២៣។

[62] *ដូចខាងលើ*។

[63] ការឆ្លើយតប កថាខណ្ឌ ២៦។

[64] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣២ និងលេខយោងជើងទំព័រ ៤១ *យោង*លើសេចក្តីសម្រេចលើការចោទប្រកាន់ [redacted] ដោយកំបាំងមុខ កថាខណ្ឌ ១៧ "នៅក្នុងករណីកម្រដែលអង្គហេតុជាក់លាក់នៃរឿងក្តីបានលើកឡើងអំពីបញ្ហាសិទ្ធិជាមូលដ្ឋានឬបញ្ហាធ្ងន់ធ្ងរនៃភាពយុត្តិធម៌ផ្នែកនីតិវិធី អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង"។

[65] សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំឲ្យពិចារណាឡើងវិញ លើការដាក់បង្ហាញឯកសារ (D193/76 និង *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់* [redacted] *សុំពេលវេលារៀបចំឲ្យបានគ្រប់គ្រាន់*

Original EN: 01539599-01539612

បណ្តឹងឧទ្ធរណ៍របស់ [redacted] អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយហេតុថា មេធាវីការពារក្តី*បានបង្ហាញ*ថា ទាល់តែអង្គបុរេជំនុំជម្រះបានអន្តរាគមន៍នៅក្នុងដំណាក់កាលនៅពេលបណ្តឹងឧទ្ធរណ៍បានដាក់ទើបសិទ្ធិរបស់ [redacted] នៅក្នុងការទទួលបានការប្រព្រឹត្តិស្មើគ្នាទទួលរង*ព្យសនកម្មមិនអាចជួសជុលបាន*[66]។

ហើយបានសន្និដ្ឋានថា ដើម្បីពិចារណាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះ "ត្រូវពិនិត្យមើលថាតើនៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះនៅក្នុងដំណាក់កាលនេះចាំបាច់ធ្វើឡើងដើម្បីទប់ស្កាត់ការរំលោភបំពានដែលមិនអាចជួសជុលបានលើសិទ្ធិរបស់ [redacted] ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ សមភាព និងភាពយុត្តិធម៌ផ្នែកនីតិវិធីដែរឬទេ"[67]។ ចំពោះទឡ្ហីករណ៍ផ្សេងៗទៀតរបស់មេធាវីការពារក្តីថា ការខកខានមិនបានទទួលយកបណ្តឹងឧទ្ធរណ៍នឹងជាការរំលោភបំពានដោយសារសហព្រះរាជអាជ្ញាអាចប្តឹងតវ៉ាដីកាសម្រេចទាំងអស់របស់ ស.ច.ស អនុលោមតាមវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅ អ.វ.ត.ក វិធានដែលចែងជាធរមានកំណត់សិទ្ធិនីតិវិធីខុសៗគ្នាក្នុងការប្តឹងតវ៉ាដោយភាគី[68] ហើយចំពោះភាពអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ការពិនិត្យបណ្តឹងឧទ្ធរណ៍ ទៅតាមករណីនីមួយៗមានគោលបំណងដើម្បីធានាសិទ្ធិរបស់ភាគីទាំងអស់។ ទោះបីជាយ៉ាងនេះក្តី មេធាវីការពារក្តីក៏យល់ស្របផងដែរថា[69] វិធាន ២១ នៃវិធានផ្ទៃក្នុងពុំបានបង្កើតយន្តការបើកឱ្យប្តឹងតវ៉ា*ដោយស្វ័យប្រវត្តិ*នោះឡើយ។

---

D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75) ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D193/91/7 ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រួម") កថាខណ្ឌ ២០ ដល់ កថាខណ្ឌ ២១។

66 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រួម កថាខណ្ឌ ២១។

67 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រួម កថាខណ្ឌ ២២។

68 *សូមមើល* វិធានផ្ទៃក្នុង វិសោធនកម្មលើកទី៩ វិធាន ៧៤(២) និងវិធាន ៧៤(៣)។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") មាត្រា ២៦៦ និងមាត្រា ២៦៧ (ការគូសបញ្ជាក់បន្ថែម)។

69 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

### *i. សិទ្ធិទទួលបានពេលវេលាសមស្រប*

២០. អង្គបុរេជំនុំជម្រះកត់សម្គាល់លើការអះអាងរបស់មេធាវីការពារក្តីថា សិទ្ធិទទួលបានពេលវេលាសមស្របក្នុងការត្រៀមរៀបចំការការពារក្តីមានភាពចាំបាច់[70] ហើយ "ឱកាសសម្រាប់ការតំណាងដោយប្រសិទ្ធភាពគឺមានសារៈសំខាន់ជាក់លាក់ ដោយហេតុថា [redacted] ប្រឈមនឹងការចោទប្រកាន់ព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុត និងដោយសារតែទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង"[71]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រៅពីការយោងលើ "ការដាក់កំហិតនីតិវិធី"[72] ហើយនឹង "ការបញ្ឈប់មុនកាលកំណត់នៃឱកាសសម្រាប់ "ធ្វើការស៊ើបសួរឱ្យបានត្រឹមត្រូវ""[73] មេធាវីការពារក្តីពុំបានបង្ហាញថាតើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានពេលវេលាសមស្របបានទទួលរងព្យសនកម្មជាក់លាក់ នៅក្នុងរឿងក្តីបច្ចុប្បន្នយ៉ាងដូចម្តេចទៅ។

២១. ម្យ៉ាងវិញទៀត ពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីក្នុងការសំអាងការលើកឡើងរបស់ខ្លួនករណីដែលថាបណ្តឹងឧទ្ធរណ៍ពុំអាចទទួលយកបាន ហើយបង្កព្យសនកម្មនាពេលបច្ចុប្បន្ន នឹងមិនអាចជួសជុលបាននៅដំណាក់ការនីតិវិធីក្រោយៗនោះទេ[74] អង្គជំនុំជម្រះពិចារណាឃើញថា ការយោងលើវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងដែលពាក់ព័ន្ធនឹងបញ្ហា*កំហុសនីតិវិធី*នៅក្នុងអំឡុងពេលស៊ើបអង្កេតពុំពាក់ព័ន្ធផ្ទាល់នឹងទឡ្ហីករណ៍ស្តីពីការខ្វះពេលវេលាសមស្របដើម្បីធ្វើ*សំណើសុំបំពេញកិច្ចស៊ើបសួរ*នៅមុនពេល ក.ស.ច.ស បញ្ជូនសំណុំរឿងឱ្យសហព្រះរាជអាជ្ញាពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា មេធាវីការពារក្តីបានដាក់សំណើសុំចំនួន ៥១ ផ្សេងទៀត[75] រួមទាំងសំណើសុំមោឃភាព ហើយនៅតែមានឱកាសដាក់សំណើសុំដូច្នេះបាន នៅមុនពេលចេញដីកាដំណោះស្រាយ។

---

[70] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤ កថាខណ្ឌ ៣៥។

[71] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។

[72] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥។

[73] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥។

[74] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦។

[75] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៤។

២២. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ មេធាវីការពារក្តីពុំបានបង្ហាញថា ការអន្តរាគមន៍របស់អង្គជំនុំជម្រះនឹងមានភាពចាំបាច់នៅក្នុងដំណាក់កាលនេះដើម្បីកុំឱ្យកើតមានការខូចខាត ដែលពុំអាចជួសជុលបានចំពោះសិទ្ធិរបស់ [redacted] ក្នុងការទទួលបានពេលវេលាសមស្របសម្រាប់ត្រៀមរៀបចំការការពារក្តីរបស់គាត់។

២៣. ចំពោះទិដ្ឋភាពមួយទៀតនៃសិទ្ធិក្នុងការទទួលបានពេលវេលាសមស្រប ដែលអង្គបុរេជំនុំជម្រះពុំបានទទួលបណ្តឹងនោះ អង្គជំនុំជម្រះកត់សម្គាល់ឃើញសេចក្តីជូនដំណឹងលើកទីពីររបស់ ស.ច.ស អំពីការបញ្ចប់កិច្ចស៊ើបសួរ។

២៤. អង្គបុរេជំនុំជម្រះសូមរំឭកឡើងវិញថា វិធាន ៦៦(១) នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

> នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគី និងមេធាវីរបស់ភាគី។ [...]។ ភាគីត្រូវមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម។

២៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា យោងតាមសេចក្តីសម្រេចនេះ កាលបរិច្ឆេទកំណត់រយៈពេល ១៥ ថ្ងៃ ក្នុងការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមគិតរាប់ក្រោយពេលមាន "ការជូនដំណឹង" អំពីការបញ្ចប់កិច្ចស៊ើបសួរ មិនថាសេចក្តីជូនដំណឹងនោះជាសេចក្តីជូនដំណឹង "លើកទីមួយ" ឬ "លើកទីពីរ" ដែលបានចេញក្រោយពេលបញ្ចប់កិច្ចស៊ើបសួរបន្ថែមនោះទេ។

២៦. អង្គជំនុំជម្រះសង្កេតឃើញទៀតថា សេចក្តីជូនដំណឹងលើកទីពីរអំពីការបញ្ចប់កិច្ចស៊ើបសួរត្រូវបានធ្វើឡើងដោយពុំបានផ្តល់ពេលវេលាជូនភាគីទៅតាមបទប្បញ្ញត្តិចែងក្នុងវិធាន ៦៦(១) នៃវិធានផ្ទៃក្នុងក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរ ក្រោយពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ។

២៧. អង្គបុរេជំនុំជម្រះពិចារណាឃើញថា អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង រយៈពេល ១៥ ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីជូនដំណឹងលើកទីពីរអំពីការបញ្ចប់កិច្ចស៊ើបសួរគួរណាស់ផ្តល់ជូនភាគីដើម្បីពិនិត្យមើលឡើងវិញលើភស្តុតាង*ដែលទើបតែប្រមូលបានថ្មី*។

### *ii. សមភាពរវាងគូភាគីក្តី*

២៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអំពីសមភាពរវាងគូភាគីក្តីបានសំអាងលើការសន្មតថា មេធាវីការពារក្តីបានបង្ហាញការខ្វះពេលវេលា

គ្រប់គ្រាន់ក្នុងការធ្វើសំណើសុំចាំបាច់ឱ្យបំពេញកិច្ចស៊ើបសួរ នៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ[76]។ ដោយសារពុំមានការបង្ហាញឱ្យឃើញនូវការរំលោភសិទ្ធិក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់[77] អង្គជំនុំជម្រះមិនធ្វើការសម្រេចលើការអះអាងពាក់ព័ន្ធថាមានការរំលោភលើសិទ្ធិសមភាពរវាងគូភាគីក្តីនេះឡើយ។

២៩. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គបុរេជំនុំជម្រះពុំចាំបាច់អន្តរាគមន៍លើករណីមួយនេះទេ។

*iii. ភាពយុត្តិធម៌ផ្នែកនីតិវិធី*

៣០. មេធាវីការពារក្តីចោទប្រកាន់បន្ថែមទៀតថា សិទ្ធិរបស់ [redacted] ក្នុងការទទួលបានភាពយុត្តិធម៌ផ្នែកនីតិវិធីកំពុងទទួលរងព្យសនកម្ម ដោយសារមេធាវីការពារក្តីត្រូវបាន "រារាំងយ៉ាងអយុត្តិធម៌" មិនឱ្យបំពេញភារកិច្ចវិជ្ជាជីវៈរបស់ខ្លួនដោយហេតុថា (i) "ការអនុញ្ញាតឱ្យចូលរួមក្នុងសំណុំរឿង ០០៤ មានភាពយឺតយ៉ាវ" ហើយចំពោះករណីអនុញ្ញាត "ឱ្យចូលរួមក្នុងសំណុំរឿង" ក្នុងដំណាក់កាលក្រោយវិញ គឺដោយហេតុថា (ii) ពេលវេលាមិនគ្រប់គ្រាន់ក្នុងការស្វែងយល់សម្ភារៈឯកសារនៅក្នុងសំណុំរឿង។ ដូច្នេះហើយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញដំបូងថា សិទ្ធិចូលពិនិត្យមើលសំណុំរឿងត្រូវបានផ្តល់ជូនមេធាវីការពារក្តី *អនុលោមតាមបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង* ដែលចែងអំពីសិទ្ធិនីតិវិធីខុសៗគ្នាសម្រាប់ "ជនត្រូវចោទ" និង "ជនសង្ស័យ"[78] ដែលករណីនេះជាការ

---

[76] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨៖ "[redacted] នឹងស្ថិតនៅក្នុងស្ថានភាពខាតប្រយោជន៍ផ្នែកនីតិវិធីសំខាន់ *ក្នុងការតទល់ជាមួយ* សហព្រះរាជអាជ្ញា ប្រសិនបើមេធាវីការពារក្តីមិនទទួលបានឱកាសគ្រប់គ្រាន់ដើម្បីស្វែងយល់ដឹងអំពីសំណុំរឿង ដែលខ្លួនអាចមានលទ្ធភាពធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរចាំបាច់ទាំងអស់ និងញត្តិចាំបាច់ផ្សេងៗមុននឹងការបញ្ចប់ការស៊ើបសួរ"។

[77] *ដូចខាងលើ* កថាខណ្ឌ ២២។

[78] *សូមមើល* សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើសុំជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D186/3 កថាខណ្ឌ ៣៣៖ "ជនសង្ស័យមិនទាន់ត្រូវបានចោទជាផ្លូវការ ហើយគាត់មិនត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារកិច្ចស៊ើបសួរដោយខុសពីវិធានផ្ទៃក្នុងឡើយ។ ដូច្នេះ សំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿងនៅដំណាក់កាលនេះត្រូវបានបដិសេធ"។ *សូមមើលផងដែរ* សំណុំរឿង ០០៤ (អ.ប.ជ ១០) ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធសំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D186/3/1/2 កថាខណ្ឌ ២៨៖ "មានការយោងផងដែរទៅលើវិធាន ៥៥(៦) នៃវិធានផ្ទៃក្នុង



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ទាត់ចោលការអះអាងអំពី "ការអនុញ្ញាតឱ្យចូលរួម" យឺតយ៉ាវមិនយុត្តិធម៌ ហើយចំណុចទីពីរ អង្គជំនុំជម្រះសូមរំឭកឡើងវិញនូវការសម្រេចរបស់ខ្លួននៅក្នុងរឿងក្តីនេះថា មេធាវីការពារក្តីពុំបាន បង្ហាញភស្តុតាងឱ្យឃើញនូវការរំលោភសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់នោះទេ[79]។

៣១. ពាក់ព័ន្ធនឹងការចោទប្រកាន់របស់មេធាវីការពារក្តីអំពីភាពអយុត្តិធម៌ដោយសារចៅក្រម "ប្រធុយ ប្រធាន" និងការផ្តល់ប្រយោជន៍ជូន ស.ព.អ ច្រើនជាងមេធាវីការពារក្តី[80] ដែលយោងតាមមេធាវី ការពារក្តី វាគឺជាអសមភាពផ្នែកនីតិវិធីនៅក្នុងរឿងក្តីនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញសេចក្តី ថ្លែងការណ៍របស់ ស.ច.ស ដោយគ្មានស្រពិចស្រពិលថា "វាជាលក្ខណៈយន្តការនៅ អ.វ.ត.ក និង ជាកាតព្វកិច្ចរបស់ ស.ព.អ ក្នុងការបញ្ជាក់ពីភស្តុតាងដែល ស.ព.អ មានប្រៀបមុន នៅក្នុងកិច្ច ស៊ើបសួរដូចបានពន្យល់ពីមុនរួចហើយ"[81] ហើយ "នៅពេលដែលរឿងក្តីនៅចំពោះមុខ ក.ស.ច.ស ហើយនោះ *សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការចូលរួម ឬ អនុវត្តកិច្ចស៊ើបសួរគឺលែងខ្លាំងជាង សិទ្ធិរបស់មេធាវីការពារក្តី* ឬ ភាគីផ្សេងទៀតហើយ"[82]។ ទោះក្នុងករណីណាក៏ដោយ ដរាបណា ពុំមានភស្តុតាងលើកមកបង្ហាញដើម្បីតតាំងសច្ចធារណ៍ នៃភាពមិនលម្អៀងរបស់ចៅក្រម[83] អង្គ ជំនុំជម្រះមិនអាចសម្រេចលើការអះអាងថា ផលប្រយោជន៍របស់ ស.ព.អ *អាច*ត្រូវបានផ្តល់ ជូនច្រើនជាងភាគីផ្សេងនោះទេ។

៣២. មេធាវីការពារក្តីលើកឡើងបន្ថែមអំពីកង្វល់ផ្សេងទៀតពាក់ព័ន្ធនឹង "ការប្រព្រឹត្តិដោយរហ័ស នៃ សំណុំរឿងប្រឆាំងនឹង [redacted]" និង "ការបញ្ចប់កិច្ចស៊ើបសួរដោយប្រញាប់" ដើម្បីសំអាងលើ

---

ដែលចែងអំពីនីតិវិធីដែលយកមកអនុវត្តចំពោះសិទ្ធិចូលពិនិត្យមើលសំណុំរឿង។ វិធាននីមួយៗក្នុងចំណោមវិធានទាំងនេះដែល ពិពណ៌នាអំពីសិទ្ធិផ្នែកនីតិវិធីយោងយ៉ាងច្បាស់ទៅលើពាក្យ "ជនត្រូវចោទ" មិនមែនយោងទៅលើពាក្យ "ជនសង្ស័យ" ឡើយ"។

[79] *ដូចខាងលើ* កថាខណ្ឌ ២២។

[80] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤២។

[81] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៧។

[82] ដីកាសម្រេចដែលរងការជំទាស់ លេខយោង ៤៩ *ដែលយោងលើ*សំណុំរឿង ០០៤ ឯកសារ D308 សេចក្តីសម្រេចលើសំណើ របស់ [redacted] សុំឱ្យសហចៅក្រមស៊ើបអង្កេតចុះពិនិត្យដល់ទីតាំង ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ១៥។

[83] សំណុំរឿង ០០២ (PTC01) ឯកសារ C11/29 សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវី ជនត្រូវចោទ [redacted] ចំពោះលោកចៅក្រម [redacted] កថាខណ្ឌ ១៩៖ "អ្នកប្តឹងជំទាស់ត្រូវបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ដល់ អង្គបុរេជំនុំជម្រះដើម្បីឱ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ចៅក្រមដែលត្រូវបានប្តឹងចោទប្រកាន់នោះអាចមានភាពលម្អៀងពិត ប្រាកដមែន។ គឺមាននៅមានចំណុចជាមូលដ្ឋានជាច្រើន ដែលត្រូវបំពេញដើម្បីជំទាស់ទៅនឹងការសន្មតជាមុននៃភាពអនាគតិ"។

ការអះអាងថា "សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំមិនអាចត្រូវបានគ្របដណ្តប់ដោយសិទ្ធិដែលផ្ទុយតាមការសន្មតរបស់ភាគីដទៃទៀតឡើយ"[84]។ អង្គបុរេជំនុំជ្រះយល់ឃើញថា នៅក្នុងរឿងក្តីនេះ ក្រៅពីការបង្ហាញកង្វល់ទាំងនេះរបស់ខ្លួន មេធាវីការពារក្តីពុំបានបង្ហាញថា ភាពយុត្តិធម៌ផ្នែកនីតិវិធីកំពុងរងនូវព្យសនកម្ម នៅក្នុងរឿងក្តីបច្ចុប្បន្ននេះទេ។

៣៣. ចំណុចចុងក្រោយ មេធាវីការពារក្តីអះអាងថា ពុំមានការលើកឡើងសំអាងហេតុគ្រប់គ្រាន់នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ដែលចំណុចនេះវាអាចប៉ះពាល់លើសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចដែលសំអាងហេតុ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា មេធាវីការពារក្តីខកខានមិនបានបញ្ជាក់បញ្ហាទាំងនេះឲ្យបានជាក់លាក់ ដែលតម្រូវឲ្យមានការបញ្ជាក់បំភ្លឺបន្ថែម ឬ អំពីការខ្វះនូវសំអាងហេតុ។ តាមការពិតទៅ នៅក្នុងពេលប្តឹងឧទ្ធរណ៍ទាំងមូល មេធាវីការពារក្តីខ្លួនឯងបង្ហាញថា សំអាងហេតុជាច្រើនត្រូវបានផ្តល់ជូន នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់តាមរយៈការប្តឹងឧទ្ធរណ៍ប្រឆាំងនឹង "កំហុសអង្គហេតុ" នានា[85]។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា មេធាវីការពារក្តីក៏ពុំបានបង្ហាញភ័ស្តុតាងអំពីការរំលោភសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុនោះដែរ។

៣៤. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីពុំបានបង្ហាញយុត្តិកម្មសមស្របដែលអាចឲ្យអង្គបុរេជំនុំជម្រះអន្តរាគមន៍ ដើម្បីទប់ស្កាត់ការខូចខាត ដែលមិនអាចជួសជុលបានដោយផ្អែកលើបញ្ហាភាពយុត្តិធម៌ផ្នែកនីតិវិធី។

## IV. សេចក្តីសន្និដ្ឋាន

៣៥. អង្គបុរេជំនុំជម្រះពុំជឿជាក់ថា សិទ្ធិទទួលបានពេលវេលាសមស្រប សិទ្ធិទទួលបានសមភាពរវាងគូភាគីក្តី និងសិទ្ធិទទួលបានយុត្តិធម៌ផ្នែកនីតិវិធីនឹងទទួលរងនូវការខូចខាតពុំអាចជួសជុលបាននោះទេ ប្រសិនបើខ្លួនមិនអន្តរាគមន៍នៅក្នុងដំណាក់កាលនេះ។ ហេតុដូច្នេះ មេធាវីការពារក្តីពុំបានបំពេញតាមលក្ខខណ្ឌអប្បបរមាស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

---

[84] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។

[85] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៦ ដល់ កថាខណ្ឌ ៧៥ *និងលេខយោងជើងទំព័រ ៥៨, ៥៩, ៦១, ៦២, ៧០, ៧៦, ៧៧, ៨៧, ៩៥ ៩៧, ១០០, ១០១, ១០៥, ១០៦, ១០៧, ១០៩, ១១០, ១១១*។

៣៦. អាស្រ័យហេតុនេះ[86] អង្គបុរេជំនុំជម្រះច្រានចោលសំណើសុំរបស់មេធាវីការពារក្តីថា អង្គបុរេជំនុំជម្រះគួរប្រើប្រាស់ឆន្ទានុសិទ្ធិ ដែលខ្លួនមានជាប់មកជាមួយដើម្បីផ្អាកដីកាសម្រេចបញ្ចប់រយៈពេលពាក់ព័ន្ធកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧។

**ហេតុដូចនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

- **មិនអាច**ទទួលបណ្តឹងឧទ្ធរណ៍នេះបាន។
- **ច្រានចោល**សំណើសុំព្យួរដីកាដែលពាក់ព័ន្ធ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន Olivier BEAUVALLET និយ ថុល Kang Jin BAIK ហួត វុទ្ធី**

[86] *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំព្យួរ កថាខណ្ឌ ៥។